# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាពេលទទួលស្វាគមន៍សម្តេចប៉ាបមកទស្សនកិច្ចព្រះសហគមន៍នៅទ្វីបអាស៊ី
# ប្រទេសថៃ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩
## ឲ្យព្រះបន្ទូលចូលនៅក្នុងវប្បធម៌

**អត្ថបទទី១៖ ម៉ាកាបាយទី១ ៤,៣៦-៣៧.៥២-៥៩**

ប្រជាជនមានអំណរសប្បាយយ៉ាងក្រៃលែង ហើយលុបលាងការអាម៉ាស់ ដែលគេទទួលពីសាសន៍ដទៃពីពេលមុន។ ១មបា ៤,៥៨

**អត្ថបទទី២៖ របាក្សត្រទី១ ២៩,១០-១២**

ព្រះអង្គជាប្រភពនៃទ្រព្យសម្បត្តិ និងសិរីរុងរឿង ហើយព្រះអង្គគ្រប់គ្រងលើអ្វីៗទាំងអស់។ ១របា ២៩,១២ក

**ដំណឹងល្អ៖ លូកា ១៩,៤៥-៤៨**

ក្នុងគម្ពីរមានចែងថា "ដំណាក់របស់យើងជាកន្លែងសម្រាប់អធិស្ឋាន" តែអ្នករាល់គ្នាបែរជាយកធ្វើសម្បុកចោរទៅវិញ។ លក ១៩,៤៥

បងប្អូនជាទីស្រឡាញ់!

យើងបានចូលនៅក្នុងបរិយាកាសពិសេស គឺបរិយាកាសនៃព្រះសហគមន៍នៅក្នុងទ្វីបអាស៊ី មានខ្មែរយើង មានថៃ មានវៀតណាម មានមីយ៉ាន់ម៉ា មានហ្វីលីពីន មានឡាវ មានឥណ្ឌា មាននេប៉ាល់ មានជប៉ុន មានកូរ៉េ...។ ព្រះសហគមន៍របស់យើង មិនមែនជាព្រះសហគមន៍តូចតាចមួយតែជាព្រះសហគមន៍យ៉ាងធំណាស់។ នៅក្នុងទ្វីបអាស៊ី យើងមានគ្រីស្តបរិស័ទតែ៣%នៃប្រជាជនទាំងអស់ ពេលយើងចូលអភិបូជាជាមួយគ្រីស្តបរិស័ទដែលមកពីគ្រប់ប្រទេសនៅទ្វីបអាស៊ីយើងដើម្បីស្វាគមន៍សម្តេចប៉ាប ណែនាំឲ្យយើងកក់ក្តៅ។ ម្សិលមិញ សម្តេចប៉ាបបានទៅជួបជាមួយនាយករដ្ឋមន្ត្រីថៃ ជួបជាមួយអ្នកជំងឺនិងបុគ្គលិកនៅមន្ទីរពេទ្យសន្តលូវីស។ នៅក្នុងធម្មទេសនារបស់សម្តេចប៉ាប ព្រះអង្គបានជម្រុញយើងឲ្យយើងទៅជាសាវ័កដែលប្រកាសដំណឹងល្អ។ សម្តេចប៉ាប ណែនាំឲ្យយើងនឹករឭកដល់៣៥០ឆ្នាំមុនដែលមានសាសនទូតមកពីទ្វីបអឺរ៉ុបដើម្បីប្រកាសដំណឹងល្អនៅក្នុងប្រទេសថៃ។ ជាឱកាសមួយ ដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ចាប់ផ្តើមចូលនៅក្នុងវប្បធម៌ថ្មី ទោះបីសាសនទូតដែលមកពីប្រទេសផ្សេងដោយមានទំលាប់គេមានរបៀបគេ នៅពេលគេចូលនៅក្នុងវប្បធម៌ថ្មីគេត្រូវការទទួលស្វាគមន៍នៅក្នុងវប្បធម៌នេះ។ អ្វីដែលណែនាំឲ្យភ្ញាក់ស្មារតី ដើម្បីណែនាំឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលយើងបានទទួលអាចចូលនៅក្នុងវប្បធម៌ថ្មីនេះ និងធ្វើដំណើរជាមួយវប្បធម៌នេះ។ កុំឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ ទៅជាព្រះបន្ទូលមួយដែលផ្សេងៗពីប្រពៃណី ផ្សេងពីវប្បធម៌ ផ្សេងពីរបៀបរបស់ប្រជាជន

ផ្ទុយទៅវិញឲ្យព្រះបន្ទូលចូលនៅក្នុងវប្បធម៌យ៉ាងជ្រៅ ដើម្បីណែនាំឲ្យវប្បធម៌នេះកែប្រែ និង ទទួលព្រះពន្លឺពីព្រះជាម្ចាស់។

ពេលយើងប្រកាសដំណឹងល្អ ដូចយើងទទួលវប្បធម៌របស់យើងផ្ទាល់រួមជាមួយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលទៅជាពន្លឺថ្មីដើម្បីឲ្យយើងទទួលស្មារតីថ្មីនៅក្នុងជីវិតរបស់យើង។ សម្ដេចប៉ាប បានបន្ថែមថា ធ្វើដូចម្ដេចដើម្បីឲ្យយើងសព្វថ្ងៃដែលជាគ្រីស្តបរិស័ទដែលរស់នៅក្នុងសង្គមបច្ចុប្បន្ននេះប្រកាសដំណឹងល្អ ឲ្យយើងចែករំលែកអំណរសប្បាយនៃដំណឹងល្អដល់បងប្អូនដែលមិនទាន់ស្គាល់ព្រះយេស៊ូ។ បញ្ហាធំដែលមាននៅក្នុងសង្គម បីដូចជាកូនក្មេង យុវជនយុវនារីដែលបានរស់នៅដោយលក់ខ្លួន ប្រើប្រាស់គ្រឿងញៀន កម្មករចំណាកស្រុក បញ្ហាដែលមាននៅក្នុងសង្គមដើម្បីឲ្យយើងភ្ញាក់ស្មារតី។ គ្រីស្តបរិស័ទមិនរស់នៅក្នុងសំបុកមួយដែលមិនដឹងអំពីអ្វីនៅជុំវិញយើង គ្រីស្តបរិស័ទរស់នៅក្នុងសង្គមនិងត្រូវការមើលឃើញគ្រប់បញ្ហាដែលមាននៅក្នុងសង្គម។ គ្រីស្តបរិស័ទម្នាក់ៗ ដូចជាមានសមត្ថភាពច្រើនជាសាសនទូតទៅទៀត ដែលបានប្រកាសដំណឹងល្អនៅក្នុងតំបន់ដែលយើងរស់នៅ ដោយអញ្ជើញមិត្តភក្តិឲ្យស្គាល់ព្រះសហគមន៍ ក្រោយមកបន្តិចម្តងៗយើងបានកសាងព្រះសហគមន៍មួយ។ ជាយើងរៀងៗខ្លួន ដែលបានត្រាស់ហៅមិត្តភក្តិ បងប្អូន គ្រួសារឲ្យស្គាល់ព្រះយេស៊ូ។

សម្ដេចប៉ាប បានថែមថា សំខាន់ឲ្យព្រះសហគមន៍របស់យើងទៅជាគ្រួសារមួយដែលសម្ដែងធម៌មេត្តាករុណារបស់ព្រះបិតា គ្រួសារមួយដែលណែនាំឲ្យអ្នកដែលចូលជាសមាជិកគ្រួសារហ្នឹងដូចជាបងប្អូនបង្កើត ដោយសារយើងរកឃើញភាពកក់ក្តៅ ការលើកទឹកចិត្ត។ នៅក្នុងព្រះសហគមន៍ យើងជាគ្រីស្តបរិស័ទដែលធ្វើដំណើរជាមួយគ្នា ជាឪពុកម្ដាយសម្រាប់បងប្អូនឯទៀតៗ។ ព្រះសហគមន៍ ជាគ្រួសារមួយដ៏ធំធេងដែលចេះស្វាគមន៍ ដែលចេះស្រឡាញ់ ដែលចេះលើកទឹកចិត្ត ដែលចេះធ្វើដំណើរជាមួយបងប្អូនទាំងអស់ ដើម្បីបង្ហាញអំពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។

ដើម្បីឲ្យយើងចូលនៅក្នុងជីវិត នៃព្រះសហគមន៍របស់យើងនៅទ្វីបអាស៊ី យើងអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គប្រទានព្រះពរដល់ព្រះសហគមន៍របស់យើងនៅប្រទេសកម្ពុជា តាមកន្លែងដែលយើងរស់នៅ តាមភូមិយើង តាមកន្លែងដែលយើងធ្វើការ ឲ្យយើងធ្វើជាសាក្សីដោយធ្វើជាមេនៅក្នុងម្សៅ។ សម្រាប់លោកអភិបាល លោកបូជាចារ្យ បងប្រុសបងស្រី យើងអាចជម្រុញ យើងអាចណែនាំ យើងអាចធ្វើដំណើរជាមួយគ្នា យើងជាគ្រីស្តបរិស័ទ យើងជាគ្រីស្តទូតដែលប្រកាសដំណឹងល្អផង យើងជាសាវ័កដែលជាមិត្តសម្លាញ់របស់ព្រះយេស៊ូផង ដើម្បីប្រកាសដំណឹងល្អនេះអស់ពីដួងចិត្ត អស់ពីជំនឿ និងអស់ពីសេចក្តីស្រឡាញ់។ យើងអរព្រះគុណព្រះជា

ម្ចាស់ ដែលបានត្រាស់ហៅយើងឲ្យធ្វើជាបុត្រាបុត្រីរបស់ព្រះអង្គ នៅក្នុងទ្វីបអាស៊ី នៅក្នុងប្រទេសកម្ពុជា អរព្រះគុណព្រះជាម្ចាស់ដែលធ្វើដំណើរជាមួយយើង និងព្រះគុណព្រះជាម្ចាស់សម្រាប់ការយាងមកសួរសុខទុក្ខរបស់សម្ដេចប៉ាប ដែលជាគ្រូគង្វាលសម្រាប់ព្រះសហាគមន៍ទូទាំងពិភពលោក។ អាម៉ែន៕